# 9 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ
## អ្នកបកប្រែភាសា



NSW DPI, Steven Honeywood

**TIS គឺជាកិច្ចបំរើជាតិដែលធ្វើការ២៤ម៉ោងក្នុងមួយថ្ងៃ។ សូមទូរស័ព្ទលេខ 131 450 ហេយប្រាប់គេថាលោកអ្នកត្រូវការអ្នកបកប្រែភាសាខ្មែរ។**



NSW DPI, Virginia Brunton

### ជាភាសារបស់លោកអ្នក

សាលាក្រុង និងក្រសួងរដ្ឋាភិបាលឯទៀតទៀតមានការប្តូរផ្តាច់ដើម្បីផ្តល់កិច្ចបំរើទាំងឡាយ ដែលអាចទទួលបាន សំរាប់ប្រជាជនដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស (NESB)។ នេះមានន័យថាលោកអ្នកគួរទទួលបាន នូវព័ត៌មានជាភាសាដែលលោកអ្នកអាចយល់បាន។

### ការទូរស័ព្ទទៅសាលាក្រុង

បើលោកអ្នកទូរស័ព្ទទៅក្រសួងរដ្ឋាភិបាលណាមួយ លោកអ្នកអាចប្រើកិច្ចបំរើបកប្រែភាសាសរសេរ និងភាសានិយាយ (TIS)។ TIS គឺជាកិច្ចបំរើជាតិដែលធ្វើការ២៤ម៉ោងក្នុងមួយថ្ងៃ។ សូមទូរស័ព្ទលេខ 131 450 ហើយប្រាប់គេនូវភាសាណាមួយដែលលោកអ្នកនិយាយ។ ប្រសិនបើលោកអ្នកទូរស័ព្ទទៅកាន់សាលាក្រុង គេនឹងមិនគិតថ្លៃ TIS ពីលោកអ្នកឡើយ។ សាលាក្រុងក៏អាចប្រើជំនួយការភាសាផងដែរ គឺជាបុគ្គលិកសាលាក្រុងដែលចេះនិយាយភាសាមួយទៀត។

### លិខិតផ្ញើទៅកាន់ និងទទួលពីសាលាក្រុង

ប្រសិនបើលោកអ្នកទទួលលិខិតណាមួយពីសាលាក្រុង នេះគឺជាការសំខាន់ដែលលោកអ្នកត្រូវឆ្លើយតបទៅនឹងលិខិតនោះឲ្យបានរហ័ស តាមលទ្ធភាពដែលអាចធ្វើទៅបាន ដ្បិតអីវាអាចប៉ះពាល់ដល់អាជីវកម្មរបស់លោកអ្នក។ ប្រសិនបើលោកអ្នកមិនអាចអានលិខិតនោះទេ ហើយពុំមានអ្នកណាម្នាក់អាចពន្យល់អំពីលិខិតនោះ សូមទាក់ទងជាមួយសាលាក្រុង។ សូមសួររកបុគ្គលិកសាលាក្រុងដែលចេះនិយាយភាសារបស់លោកអ្នក ឬអ្នកបកប្រែភាសា (TIS) ហើយស្នើសុំឲ្យគេពន្យល់លិខិតនោះជូនលោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការឆ្លើយតបជាលាយលក្ខណ៏អក្សរ លោកអ្នកអាចសរសេរជាភាសារបស់លោកអ្នកផ្ទាល់ ដោយព្រោះថាសាលាក្រុងនឹងអាចរៀបចំឲ្យមានអ្នកបកប្រែភាសា។ ទោះជាយ៉ាងណាក៏ដោយ វានឹងមានប្រយោជន៏ខ្លាំងណាស់ ប្រសិនបើលោកអ្នកសរសេរចុះឈ្មោះនៃជនដែលលោកអ្នកសរសេរលិខិតទៅកាន់ និងលេខយោង ឬកម្មវត្ថុណាមួយជាភាសាអង់គ្លេស។

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្តីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST